ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៤ សរច-៩៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

លោក ប្រធានតុលាការគ្រប់ខេត្ត ក្រុង

លោកព្រះរាជអជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** ការណែនាំអំពីនីតិវិធីប្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍របស់គូក្តី ចំពោះសាលក្រមតុលាការខេត្ត ក្រុង ។

**យោង:** មាត្រា ៧ នឹង ៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា១១១,១១២,១១៦ ,១១៧,១១៨,១១៩,១២០,១៧៦,១៧៧ និង ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

កន្លងមកក្រសួងបានសង្កេតឃើញថា តុលាការខ្លះនៅមានការខ្វះខាតក្នុងការអនុវត្តន៍បទបញ្ញត្តិ ស្តីពីការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ដើម្បីបញ្ចប់ការខ្វះខាតនេះក្រសួងសុំរំលឹកដូចតទៅ ៖

ក-អំពីដីកាកោះ ឬសេចក្តីជូនដំណឹងពីសេចក្តីសម្រេចផ្សេងៗរបស់តុលាការ៖ បញ្ហានេះតុលាការត្រូវយកចិត្តទុកដាក់ចាត់វិធានការផ្តល់ដំណឹងនេះដល់គូក្តីអោយបានត្រឹមត្រូវតាមច្បាប់កំណត់ រួចយកលិខិតដើមមកដាក់ក្នុងសំណុំរឿងវិញ ។

ខ-អំពីការជូនដំណឹងពីសាលក្រមកំបាំងមុខដល់គូក្តី ដែលមិនបានចូលខ្លួនមកចំពោះមុខតុលាកាត្រូវធ្វើយ៉ាងណាជូនដំណឹងនោះអោយបានដល់គូក្តី ហើយប្រាប់គូក្តីអោយយល់ពីសិទ្ធិរបស់គេ ដើម្បីអោយគេអាចចូលមកប្តឹងតវ៉ាទាន់ពេលវេលា ។

គ-អំពីការប្រកាសសាលក្រមចំពោះមុខគូក្តី ត្រូវប្រកាសថា សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី បើកផ្លូវឧទ្ធរណ៍កំណត់២ខែ គិតពីថ្ងៃនេះតទៅ រួចត្រូវណែនាំបន្ថែមអោយបានច្បាស់ថា បើភាគីណាមិនសុខចិត្តពីសេចក្តីសម្រេចនេះទេ ត្រូវផ្តិតជាមេដៃ ឬចុះហត្ថលេខា ប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនេះនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ ក្នុងរយៈពេល២ខែ គិតពីថ្ងៃសម្រេចសេចក្តីនេះតទៅ ។

នៅពេលដែលគូក្តីចូលមកប្តឹងឧទ្ធរណ៍ពីសាលក្រមណាមួយរបស់តុលាការ អ្នកទទួលបណ្តឹងត្រូវសួរបញ្ជាក់ដល់អ្នកប្តឹងថា តើគេប្តឹងមិនសុខចិត្តនឹងសាលក្រមទាំងមូល ឬមិនសុខចិត្តពីចំណុចណាមួយនៃសាលក្រមនោះ ក្រសួងតម្រូវអោយចៅក្រមជំនុំជម្រះពន្យល់ដល់គូក្តី ពិសេសអ្នកចាញ់ក្តីអោយបានយល់ច្បាស់លាស់អំពីសិទ្ធិប្តឹងឧទ្ធរណ៍នេះ កុំអោយអ្នកចាញ់ក្តីនោះភាន់ច្រឡំ ឬស្តាប់មិនបាន ។

ឃ-អំពីការប្តឹងឧទ្ធរណ៍ ឬប្តឹងទាស់ពីសាលក្រមរបស់តុលាការខេត្ត-ក្រុង ដោយគូក្តីណាមួយមិនត្រូវតម្រូវជាចាំបាច់អោយគូក្តីនោះធ្វើពាក្យប្តឹងទាស់ ឬឧទ្ធរណ៍ទេ គឺគ្រាន់តែអោយគូក្តីនោះផ្តិតមេដៃ ឬចុះហត្ថលេខាលើសៀវភៅបណ្តឹងតវ៉ានឹងចុះថ្ងៃ ខែ ឆ្នាំ អោយបានច្បាស់លាស់តែប៉ុណ្ណោះអាចចាត់ទុកជាបានការគ្រប់គ្រាន់តាមផ្លូវច្បាប់ហើយ ។ ប្រសិនបើអ្នកប្តឹងចង់បានសេចក្តីបញ្ជាក់ពីបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងទាស់នោះក្រឡាបញ្ជីត្រូវចេញសេចក្តីបញ្ជាក់អោយភ្លាម ។ ចំណែកសេចក្តីដែលមានចុះនៅបន្ទាត់ចុងបំផុតនៃសន្លឹកបណ្តឹង ក្នុងសៀវភៅបណ្តឹងតវ៉ាដែលថា អ្នកប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍ ត្រូវធ្វើពាក្យជូនតុលាការឱ្យបានទាន់ពេលវេលានោះពុំមានន័យថា ត្រូវអោយអ្នកប្តឹងនោះធ្វើ

ពាក្យជាមុនទើបអាចទទួលចុះបណ្តឹងទាស់ ឬបណ្តឹងឧទ្ធរណ៍អោយទេ ត្រង់នេះមានន័យថាអ្នកប្តឹងតវ៉ាត្រូវធ្វើពាក្យបង្ហាញហេតុផល និងជូនភស្តុតាងពីបណ្តឹងរបស់ខ្លួនជូនតុលាការខេត្ត-ក្រុង ដែលទទួលបណ្តឹងទាស់ឬជូនទៅសាលាឧទ្ធរណ៍អោយបានមុនពេលតុលាការបើកសវនាការធ្វើការពិភាក្សាដេញដោល ពិនិត្យលើបណ្តឹងទាស់ឬបណ្តឹងឧទ្ធរណ៍ដល់អង្គសេចក្តីតែប៉ុណ្ណោះ ។

ង-ចំពោះបណ្តឹងទាស់ តាមគោលការណ៍ គូក្តីត្រូវប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ប៉ុន្តែគូក្តីអាចប្តឹងបានដែរតាមសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតា ឬតាមបណ្តឹងធ្វើនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីនេះថ្ងៃ ខែ ឆ្នាំ ដែលប្តឹងតវ៉ាគឺកំណត់យកថ្ងៃ ខែ ឆ្នាំ ដែលត្រូវប្រៃសណីយ៍ ឬការិយាល័យនគរបាលយុត្តិធម៌បានចុះក្នុងបញ្ជីចូលទៅកន្លែងអង្គការនោះទុកជាថ្ងៃ ខែ ឆ្នាំ ដែលគូក្តីបានចូលទៅតវ៉ាក្នុងកំណត់ច្បាប់ ។

ច-ចំពោះបណ្តឹងឧទ្ធរណ៍វិញ គូក្តីត្រូវតែចូលទៅប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការសាមី តាមរយៈពេលដែលច្បាប់បានកំណត់ ថ្ងៃខែ ដែលកំណត់យកជាការនោះគឺថ្ងៃ ដែលអ្នកប្តឹងចុះហត្ថលេខា ឬផ្តិតមេដៃលើបណ្តឹងដែលចុះក្នុងបញ្ជី ។

ឆ-នៅមុខសាលាជំនុំជម្រះក្តីនៃតុលាការខេត្ត-ក្រុង នីមួយៗលោកប្រធានតុលាការត្រូវធ្វើផ្លាកដាក់ពីមុខដោយសរសេរថា ៖

**<u>សេចក្តីជូនដំណឹង</u>**

អំពីសិទ្ធិប្តឹងទាស់ សាលក្រមកំបាំងមុខ និងសិទ្ធិប្តឹងឧទ្ធរណ៍ពីសាលក្រមចំពោះមុខ

១-សាលក្រមកំបាំងមុខលើកទី១ គូក្តីណាមិនសុខចិត្តអាចប្តឹងជំទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីសេចក្តីសម្រេចរបស់តុលាការ ។

២-សាលក្រមកំបាំងមុខលើកទី២ ទុកដូចជាចំពោះមុខគូក្តី គូភាគីអាចប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល ២ខែ គិតពីថ្ងៃអោយដំណឹង ។

៣-សាលក្រមចំពោះមុខគូក្តី គូក្តីអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ២ខែ គិតពីថ្ងៃសម្រេចសេចក្តីរបស់តុលាការតទៅ ។

៤-ការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ភាគីណាមិនសុខចិត្តត្រូវចូលទៅប្តឹងតវ៉ានៅការិយាល័យក្រឡាបញ្ជីនៃតុលាការនោះ តាមរយៈពេលដូចបានកំណត់ជូនខាងលើ ។

ជ-ជាចាំបាច់ ក្រឡាបញ្ជីត្រូវចេញលិខិតបញ្ជាក់ពីករណីនីមួយៗខាងលើនេះជូនគូក្តីដើម្បីអោយគេយល់ច្បាស់អំពីសិទ្ធិរបស់គេ ។

ឈ-អំណើះតទៅ អ្នកប្រព្រឹត្តមិនសមស្រប ក្រសួងនឹងតម្រូវអោយទទួលខុសត្រូវជាវិន័យរដ្ឋបាល ដោយមិនទាន់គិតដល់ការខូចខាតប្រសិនបើមាន ។

ញ-ក្រោយពីបានទទួលសារាចរនេះ លោកប្រធានតុលាការ ខេត្ត-ក្រុង នីមួយៗត្រូវប្រជុំបុគ្គលិកទាំងអស់នៃតុលាការរៀងៗខ្លួន ហើយផ្សព្វផ្សាយអោយយល់ច្បាស់អំពីខ្លឹមសារនៃសារាចរនេះ រួចធ្វើរបាយការណ៍ត្រឡប់ទៅក្រសួងវិញជាបន្ទាន់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-តុលាការកំពូល
-តុលាការសាលាឧទ្ធរណ៍
-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍